# តើកូនរបស់អ្នកនឹងចាប់ផ្តើមចូលរៀនថ្នាក់ទី 7 នៅរដូវស្លឹកឈើជ្រុះមែនដែរឬទេ?

## ទទួលការចាក់វ៉ាក់សាំងឱ្យបានមុនរដូវស្លឹកឈើជ្រុះដើម្បីជៀសវាងភាពមមាញឹកនៅអំឡុងពេលនោះ។

វ៉ាក់សាំងជួយឱ្យកុមារមានសុខភាពល្អ ដូច្នេះពួកគេអាចបន្តធ្វើអ្វីដែលពួកគេចូលចិត្តបាន!

ត្រូវបានតម្រូវសម្រាប់ថ្នាក់ទី 7៖

- វ៉ាក់សាំងបង្ការជំងឺ តេតាណូស ខាន់ស្លាក់ និងក្អកមាន់ (Tdap).

ត្រូវបានតម្រូវសម្រាប់ថ្នាក់ K–12៖

- វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ B (Hepatitis B)
- វ៉ាក់សាំងបង្ការជំងឺ កញ្ជ្រឹល ស្អូច ស្រឡទែន (MMR)
- វ៉ាក់សាំងបង្ការជំងឺគ្រុនស្វិតដៃជើង (Polio)
- វ៉ាក់សាំងវ៉ារីសេឡា (ជំងឺអុតស្វាយ)

ត្រូវបានណែនាំ៖

- វ៉ាក់សាំងមហារីកស្បូន (HPV)
- វ៉ាក់សាំងរលាកស្រោមខួរដោយមេរោគមេណាំងហ្គូកុក (Meningococcal)
- វ៉ាក់សាំងគ្រុនផ្តាសាយ
- COVID-19
- វ៉ាក់សាំងបង្ការជំងឺរលាកថ្លើមប្រភេទ A (Hepatitis A)

## តើខ្ញុំអាចដឹងថាកូនរបស់ខ្ញុំត្រូវការវ៉ាក់សាំងដោយរបៀបណា?

សូមចូលទៅកាន់ myirmobile.com និងធ្វើការចុះឈ្មោះដើម្បីមើលកំណត់ត្រាការចាក់វ៉ាក់សាំង។ អ្នកអាចព្រីននូវវិញ្ញាបនបត្របញ្ជាក់ស្ថានភាពការចាក់វ៉ាក់សាំងសម្រាប់សាលាបាន។ អ្នកក៏អាចទាក់ទងទៅកាន់អ្នកផ្តល់សេវាថែទាំសុខភាពរបស់កូនអ្នកសម្រាប់ជំនួយផងដែរ។

## តើកូនរបស់ខ្ញុំអាចទទួលការចាក់វ៉ាក់សាំងបាននៅកន្លែងណា?

- នៅការិយាល័យរបស់អ្នកផ្តល់សេវាថែទាំសុខភាព៖ អ្នកផ្តល់សេវាអាចធ្វើឱ្យប្រាកដថាកូនរបស់អ្នកបានទទួលវ៉ាក់សាំងចាំបាច់ទាំងអស់ដែលពួកគេត្រូវការ និងធ្វើការត្រួតពិនិត្យសុខភាពសំខាន់ៗផ្សេងទៀត។
- នៅឱសថស្ថាន៖ ទូរសព្ទទៅជាមុនដើម្បីសាកសួរថាតើពួកគេ៖
  - o មានវ៉ាក់សាំងដែលកូនអ្នកត្រូវការ.
  - o មានការកម្រិតអាយុ
  - o គិតថ្លៃសេវា (សូម្បីតែជាមួយនឹងធានារ៉ាប់រង) ដែរឬទេ។
- នៅព្រឹត្តិការណ៍ចាក់វ៉ាក់សាំង៖ សូមចូលទៅកាន់ tpchd.org/kidsvax សម្រាប់ទីតាំង។

Tacoma-Pierce County
Health Department
*Healthy People in Healthy Communities*